**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ២៦៣៥ ដនស

**សារលិខិតអបអរសាទរ**

**សូមគោរពជូន**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមសម្តែងនូវសេចក្តីសោមនស្សរីករាយឥតឧបមា និងអំណរសាទរយ៉ាងក្លៀវក្លាបំផុតក្នុងឱកាសដែល **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគោរមងារជា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ។

ការប្រោសព្រះរាជទានគោរមងារជា **សម្តេចមហាបវរធិបតី** ពិតជាស័ក្តិសមបំផុតចំពោះ **សម្តេច** ដែលជាយុវជនឆ្នើម និងជាប្រមុខរាជរដ្ឋាភិបាលពោរពេញដោយចំណេះដឹងជ្រៅជ្រះ សមត្ថភាព ធន្ទះ ឧត្តមគតិ និងសក្តានុពលដ៏ខ្លាំងក្លាក្នុងការដឹកនាំព្រះរាជាណាចក្រកម្ពុជា ការពារសុខសន្តិភាព ជានាស្ថិរភាពនយោបាយ ពូនជ្រំនូវមរតកដ៏ថ្លៃថ្លាបំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ «ព្រះបរមរតនកោដ្ឋ» ព្រះបិតាឯករាជ្យ** និង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បិតាសន្តិភាព** ។ នៅក្នុងអាណត្តិនៃរាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ ជវភាព និងទស្សនវិស័យទំនើបជឿនលឿនរបស់ **សម្តេចមហាបវរធិបតី** ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្តេជ្ញាឆ្លើយតបនឹងការបន្តដំណើររបស់កម្ពុជា ស្របតាមស្មារតីនៃយុទ្ធសាស្ត្របញ្ចកោណ គោលនយោបាយរាជរដ្ឋាភិបាល និងជាពិសេសគោលនយោបាយជាអាទិភាពទាំង៦ ដើម្បីឆ្ពោះទៅការកសាងកម្ពុជាសហសម័យ ប្រកបដោយឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត្យ វឌ្ឍនភាពសង្គម ស្មើមុខស្មើមាត់លើឆាកអន្តរជាតិ និងប្រជាជនមានជីវភាពកាន់តែល្អប្រសើរ ទាំងមូលដ្ឋានសម្ភារ គំនិត និងមនសិការជាតិ។

ក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណមបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ព្រមទាំងវត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេព្តារក្សាព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាអភិបាលប្រោះព្រំសព្ទសាធុការពរជ័យបវរសួស្តី ជ័យមង្គល និងវិបុលសុខគ្រប់ប្រការ ជូនចំពោះ **សម្តេចមហាបវរធិបតី** និង **លោកជំទាវ** ព្រមទាំងបុត្រាបុត្រីជាទីស្រឡាញ់ សូមបានប្រកបនូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍។

សូម **សម្តេចមហាបវរធិបតី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សៅរ៍ ២រោច ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

អាសយដ្ឋាន: ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com